## ១ សញ្ញាសម្គាល់សម្រាប់គោរមងារ អភិសន្តិបណ្ឌិត

### ក- រូបសញ្ញា




### ខ- សញ្ញាសម្គាល់សម្រាប់គោរមងារ អភិសន្តិបណ្ឌិត

មានទម្រង់និងអត្ថន័យដូចខាងក្រោម៖

**ខ.១- ទម្រង់**

- មានរូបរាងជាផ្កាឈូកក្រពុំ រំលេចទៅដោយសន្លឹកក្បាច់អង្គរពទ្ធខាងក្រៅពណ៌មាស ទំហំកម្ពស់២៥ម.ម. និងទទឹង១៦ម.ម.

- ផ្នែកខាងលើមានមកុដរាជបញ្ចេញពន្លឺរង្សីពណ៌មាសចំនួន២៥និងមានសញ្ញាឱមពណ៌មាសនៅខាងក្រោម
- ផ្នែកខាងក្នុងចំកណ្តាលមានកងចក្រពណ៌មាសចំនួន២៥ ដែលរំលេចទៅដោយរូបនាគពណ៌មាសចំនួនពីរអមត្រីសូលព៌ណ៌មាសនៅចំកណ្ដាល។ រីឯនៅខាងក្រោមកងចក្រ រំលេចដោយក្រណាត់បូ ពណ៌ក្រហម ខៀវ ហើយក្នុងផ្ទៃបូមានសរសេរពាក្យថា **«អភិសន្តិបណ្ឌិត-ABHISANTIBINDIT»** ពណ៌មាស ដែលទ្រដោយក្បាច់ភ្ញីអង្គរនៅបាតខាងក្រោម។

**ខ.២- អត្ថន័យ**

- **ក្បាច់អង្គរពទ្ធជុំវិញ** តំណាងឱ្យនិមិត្តរូបនៃវប្បធម៌ដ៏រុងរឿងខ្ពស់ត្រដែតនាសម័យអង្គរ ប្រកបដោយសុខសន្តិភាពនិងការអភិវឌ្ឍ
- **ពន្លឺឆព្វណ្ណរង្សី** ស្ថិតនៅពីលើគេ តំណាងឱ្យគំនិត ប្រាជ្ញា ស្មារតី
- **មកុដរាជ** តំណាងឱ្យអំណាចរបស់ព្រះមហាក្សត្រ ដែលផ្ដល់ជាម្លប់ដ៏ត្រជាក់ដល់ប្រជានុរាស្ត្រនិងសិទ្ធិអំណាចដល់ស្ថាប័នជាតិ ក្នុងការថែរក្សាការពារសន្តិសុខ សណ្ដាប់ធ្នាប់ទូទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- **សញ្ញាឱម** តំណាងឱ្យអំណាចកំពូលដែលមានការគាំទ្រពីថ្នាក់ក្រោមនិងប្រជារាស្ត្រ
- **កងចក្រ** តំណាងឱ្យប្រសិទ្ធភាព អំណាច និងសមត្ថកិច្ចក្នុងការអនុវត្តភារកិច្ចថែរក្សាសន្តិសុខនិងសណ្ដាប់ធ្នាប់សង្គមទូទាំង២៥រាជធានី ខេត្ត
- **ត្រីសូល** តំណាងឱ្យតេជៈ សិទ្ធិអំណាច តួនាទី ភារៈល្អ រក្សាការពារ និងកសាង
- **នាគ** តំណាងឱ្យអំណាចបារមី ការផ្ដល់នូវភាពត្រជាក់ត្រជុំ សុខដុមរមនា ការការពារ និងថែរក្សាសម្បត្តិទ្រព្យ ប្រកបដោយវិទ្ធានុភាពដល់ប្រជាពលរដ្ឋ
- **បូពណ៌ខៀវ** និង **ក្រហម** រំលេចគោរមងារ **អភិសន្តិបណ្ឌិត-ABHISANTIBINDIT** ពណ៌មាសនៅចំកណ្ដាល តំណាងឱ្យសន្តិសុខ សុវត្ថិភាពសង្គម សុខសន្តិភាព សាមគ្គីភាព ភាតរភាព និងនិរន្តរភាព ព្រមទាំងបង្ហាញពីភាពមោះមុត អង់អាចក្លាហាន ការប្ដេជ្ញាចិត្ត ហ៊ានធ្វើពលិកម្ម និងតស៊ូ ប្រយុទ្ធរបស់កងកម្លាំងនគរបាលជាតិក្នុងការបម្រើជាតិនិងប្រជាពលរដ្ឋ
- **ពណ៌មាស** តំណាងឱ្យពន្លឺនៃវិជ្ជាអប់រំបញ្ញា ប្រាជ្ញាស្មារតី ភាពឧត្តុង្គឧត្តម សេចក្ដីថ្លៃថ្នូរ គុណតម្លៃកងកម្លាំង និងប្រជាពលរដ្ឋទូទាំងប្រទេសកម្ពុជា
- អក្សរ **អភិសន្តិបណ្ឌិត-ABHISANTIBINDIT** ជាឈ្មោះគោរមងារ ការផ្ដល់កិត្តិយសកម្រិតខ្ពស់បំផុតជូនថ្នាក់ដឹកនាំនៃក្រសួងមហាផ្ទៃ។